ក្រសួងអប់រំរដ្ឋ NSW

## Notice of potential expulsion - unsatisfactory participation in learning for students aged 17 years and over

Using the telephone interpreter service to contact the school

# សេចក្តីជូនដំណឹងអំពីការបណ្តេញចេញដែលមានសក្តានុពល - ការចូលរួមក្នុងការរៀនសូត្រមិនសមតាមបំណង សម្រាប់សិស្សដែលមានអាយុចាប់ពី 17 ឆ្នាំឡើងទៅ

## ការប្រើសេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ ដើម្បីទាក់ទងសាលារៀន

ឈ្មោះសិស្ស
Name of student

សូមគោរពឪពុកម្តាយ/អ្នកថែទាំ

លិខិតដែលភ្ជាប់មកជាមួយនេះ រៀបរាប់លម្អិតនៃសេចក្តីជូនដំណឹងអំពីការបណ្តេញចេញដែលមានសក្តានុពល - ការចូលរួមក្នុងការរៀនសូត្រមិនសមតាមបំណង ដែលខ្ញុំបានចេញឱ្យកូនរបស់អ្នក ដោយអនុលោមតាមគោលនយោបាយអាកប្បកិរិយាសិស្សរបស់ក្រសួងអប់រំរដ្ឋ NSW និងនីតិវិធីការបញ្ឈប់បណ្តោះអាសន្ន និងការបណ្តេញចេញ។

លិខិតនេះអញ្ជើញអ្នកឱ្យចូលរួមកិច្ចប្រជុំផ្លូវការមួយដើម្បីពិភាក្សាអំពីរឿងនេះ មុនពេលការសម្រេចចិត្តណាមួយក្នុងការបណ្តេញចេញត្រូវបានធ្វើឡើង។ នៅពេលសាលារៀនទាក់ទងមកអ្នក សូមប្រាប់យើងឱ្យដឹង ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់នៅឯកិច្ចប្រជុំ ហើយយើងនឹងរៀបចំជូនអ្នក។ ប្រសិនបើអ្នកមានការពិបាកយល់អំពីលិខិតដែលភ្ជាប់មកជាមួយ សូមទាក់ទងសាលារៀនដើម្បីឱ្យពួកយើងអាចពន្យល់ជូនអ្នក។

អ្នកត្រូវបានស្នើសុំឱ្យឆ្លើយតបទៅនឹងការទទួលបាននូវ សេចក្តីជូនដំណឹងអំពីការបណ្តេញចេញដែលមានសក្តានុពល - ការចូលរួមក្នុងការរៀនសូត្រមិនសមតាមបំណង។ ទម្រង់បែបបទដាច់ដោយឡែកមួយបានដាក់ភ្ជាប់សម្រាប់គោលបំណងនេះ។ ភ្ជាប់មកជាមួយនេះផងដែរ គឺជាព័ត៌មាននិយាយអំពីអ្វីៗដែលអ្នកចាំបាច់ត្រូវដឹង ប្រសិនបើកូនរបស់អ្នកត្រូវបានបណ្តេញចេញ។

ប្រសិនបើអ្នកត្រូវការជំនួយអ្នកបកប្រែផ្ទាល់មាត់ នៅពេលទាក់ទងសាលារៀន សូមហៅទូរសព្ទលេខ 131 450 ហើយស្នើសុំអ្នកបកប្រែផ្ទាល់មាត់ជាភាសារបស់អ្នក។ ប្រាប់ការីទូរសព្ទនូវលេខទូរសព្ទដែលអ្នកចង់ហៅ ហើយការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់ម្នាក់ដើម្បីជួយអ្នកក្នុងការសន្ទនា។ គេនឹងមិនគិតថ្លៃសេវានេះពីអ្នកទេ។

ឈ្មោះនាយកសាលា
Name of Principal

លេខទូរសព្ទរបស់នាយកសាលា
Principal's phone number

## សេចក្ដីជូនដំណឹងអំពីការបណ្ដេញចេញដែលមានសក្ដានុពល - ការចូលរួមក្នុងការរៀនសូត្រមិនសមតាមបំណង សម្រាប់សិស្សដែលមានអាយុចាប់ពី 17 ឆ្នាំឡើងទៅ - ការឆ្លើយតបរបស់ឪពុកម្ដាយ/អ្នកថែទាំ

## Notice of potential expulsion - unsatisfactory participation in learning for students aged 17 years and over - Parent/carer response

**សូមប្រគល់ទម្រង់បែបបទនេះទៅអាសយដ្ឋានអ៊ីមែលដែលមានរាយខាងក្រោម ឬទៅការិយាល័យសាលា**

ឈ្មោះសិស្ស
Name of student ______________________________

អាសយដ្ឋានអ៊ីមែលសាលាដើម្បីប្រគល់ជូនការឆ្លើយតប
School email address for return of response ______________________________

**ឪពុកម្ដាយ/អ្នកថែទាំ ត្រូវបំពេញព័ត៌មានលម្អិតខាងក្រោមជាភាសាអង់គ្លេស**

- ☐ ខ្ញុំបានពិភាក្សាអំពីរឿងនេះជាមួយកូនរបស់ខ្ញុំ ហើយបានកត់សម្គាល់ សេចក្ដីជូនដំណឹងអំពីការបណ្ដេញចេញ ដែលមានសក្ដានុពលចំពោះការចូលរួមមិនសមតាមបំណង។
I have discussed this matter with my child and have noted the notice of potential expulsion for unsatisfactory participation.
- ☐ ខ្ញុំនឹងជួបជាមួយសាលារៀនឱ្យបានឆាប់ តាមដែលអាចធ្វើទៅបាន ដើម្បីពិភាក្សាអំពីរឿងនេះ។
I will meet with the school as soon as possible to discuss this matter.
- ☐ ជាជម្រើស - ខ្ញុំនឹងនាំអ្នកគាំទ្រម្នាក់មកចូលរួមកិច្ចប្រជុំជាមួយខ្ញុំ។
Optional - I will bring a support person to attend the meeting with me.
- ☐ ជាជម្រើស - ខ្ញុំនឹងត្រូវការអ្នកបកប្រែផ្ទាល់មាត់នៅឯកិច្ចប្រជុំ។
Optional - I will need an interpreter at the meeting.

ឈ្មោះឪពុកម្ដាយ/អ្នកថែទាំ (សូមសរសេរជាអក្សរពុម្ព) ______________________________
Name of parent/carer

ហត្ថលេខារបស់ឪពុកម្ដាយ/អ្នកថែទាំ ______________________ កាលបរិច្ឆេទ ____________
Signature of parent/carer — Date

ឪពុកម្ដាយ/អ្នកថែទាំ ត្រូវផ្ដល់ព័ត៌មានលម្អិតនៃវិធីទំនាក់ទំនងដែលចូលចិត្ត ឧទាហរណ៍ លេខទូរសព្ទ អាសយដ្ឋានអ៊ីមែល

វិធីទំនាក់ទំនងដែលខ្ញុំចូលចិត្តគឺ៖ ______________________________
Parent's/carer's preferred contact method

ព័ត៌មានទំនាក់ទំនងរបស់ខ្ញុំគឺ៖ ______________________________
Parent's/carer's contact details